ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

**ការកាត់ដីទំហំ ១៧,៥០ ហិកតា នៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ចេញពីដីក្នុងតំបន់ ២ នៃបឹងទន្លេសាប និងសារាចរណែនាំ ០២ សរណន ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែកសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៤១៦ /៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បកចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរណន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ និងប្រើប្រាស់ជាក់ស្តែងនៅតំបន់វាលទំនាបដេលលិចទឹកក្នុងរដូវវដំឡើង នៃដែនដីដែលទទួលរបបទឹកទន្លេមេគង្គ
- លិខិត ១៥៩/១៦ លស ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : កាត់ផ្ទៃដីសរុបទំហំ **១៧,៥០ ហិកតា** ចេញពីដីក្នុងតំបន់ ២ នៃបឹងទន្លេសាប និងសារាចរណែនាំ ០២ សរណន ចុះថ្ងៃ២៧ ខែមីនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាល ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ **១២,៥០ហិកតា** សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកជាដីសាធារណៈទំហំ **៥ ហិកតា** សម្រាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ស្ថិតនៅសង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុង**មាត្រា១** ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **ចំនួន ៥២៥ គ្រួសារ** ដែលត្រូវបានផ្លាស់ប្តូរទីតាំងថ្មី **នៅភូមិទី៦** សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

**មាត្រា ៣** : ផ្តល់សិទ្ធិសរុបចំនួន **៥៣១ ក្បាលដី** ក្នុងនោះ **៥២៥ ក្បាលដី** ផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន **៥២៥ គ្រួសារ** និង **០៦ ក្បាលដី** ផ្តល់សិទ្ធិសាងសង់ សាលាបុណ្យ ០១ ក្បាលដី, **ទីផ្សារនិងចំណតរថយន្ត ០១ ក្បាលដី** និងសួនច្បារសាធារណៈ ០៤ ក្បាលដី ស្ថិតក្នុង**ភូមិទី៦** សង្កាត់ខ្សាម **ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង** ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី...០៨.....ខែភទ្របទ....ឆ្នាំ ២០១៦ ស្តីពីការកាត់ដីទំហំ ១៧.៥០ ហិកតា នៅ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ចេញពីដីក្នុងតំបន់ ២ នៃបឹងទន្លេសាប និងសារាចរណែនាំ ០២ សរណន ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទិ ជូនប្រជាពលរដ្ឋ និងមួយចំណែកសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ




| ID | E | N |
|---|---|---|
| 1 | 463804 | 1357495 |
| 2 | 463538 | 1357931 |
| 3 | 463180 | 1357811 |
| 4 | 463250 | 1357609 |
| 5 | 463404 | 1357725 |
| 6 | 463495 | 1357328 |